# វិញ្ញាសាគំរូ ការប្រឡងវាយតម្លៃពលករជំនាញកម្រិត 1 ផ្នែកសំណង់ (ការប្រឡងទ្រឹស្តី)

សំណួរទី 1
ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង (          ) ក្នុងប្រយោគខាងក្រោម។

ដើម្បីធ្វើឲ្យការសាងសង់មានដំណើរការរលូន (          ) ក្នុងចំណោមអ្នកម៉ៅការឯកទេស គឺមានសារៈសំខាន់។

1. ការដែលមិនចាប់អារម្មណ៍
2. ការងារជាក្រុម

ចម្លើយ៖ 2

សំណួរទី 2
ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង(          ) ក្នុងប្រយោគខាងក្រោម។

ជាទូទៅ នៅចុងបញ្ចប់នៃការប្រជុំពេលព្រឹក គេចាប់គូគ្នា 2នាក់ អនុវត្ត(          ) ដោយបញ្ចេញសំឡេងឮៗ។

1. ការវកិច្ច
2. ហាត់ប្រាណ
3. ការពិនិត្យបញ្ជាក់សុវត្ថិភាព

ចម្លើយ៖ 3

សំណួរទី 3
ទង្វើដែលផ្តល់ការឈឺចាប់ផ្លូវចិត្តផ្លូវកាយឬធ្វើឱ្យបរិយាកាសការងារមានភាពអាក្រក់ដោយប្រើប្រាស់ឧត្តមភាពក្នុងកន្លែងធ្វើការដែលហួសពីវិសាលភាពសមស្របនៃការងារ តើត្រូវបានហៅថាជាអ្វី?

1. ការបៀតបៀនដោយអំណាច
2. ការបៀតបៀនផ្លូវភេទ
3. ការបៀតបៀនដោយគ្រឿងស្រវឹង

ចម្លើយ៖ 1

សំណួរទី 4
ក្នុងម៉ោងធ្វើការស្របច្បាប់ តើម៉ោងធ្វើការក្នុង 1 ថ្ងៃគឺត្រឹមប៉ុន្មានម៉ោង?

1. 6 ម៉ោង
2. 8 ម៉ោង
3. 12 ម៉ោង

ចម្លើយៈ 2

សំណួរទី 5
ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង (　　　　) ក្នុងប្រយោគខាងក្រោម។

ក្នុងច្បាប់ស្តីពីស្តង់ដានៃការសាងសង់អគារ បានកំណត់វិធាន(　　　　) អំពីការសាងសង់និងប្រើប្រាស់អគារដើម្បីឲ្យអាចរស់នៅប្រកបដោយសុវត្ថិភាពនិងស្ងប់សុខ។

1. ដែលសុវត្ថិភាពត្រូវបានធានា
2. អប្បបរមា
3. លើសពីការចាំបាច់

ចម្លើយៈ 2

សំណួរទី 6

ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង (　　　　) ក្នុងប្រយោគខាងក្រោម។

ក្នុងគោលបំណងនៃច្បាប់ការពារអគ្គីភ័យ គឺមានការ(　　　　)ការខូចខាតដែលបណ្តាលមកពីគ្រោះមហន្តរាយដូចជាអគ្គីភ័យ ឬរញ្ជួយដី។ល។

1. បង្កើន
2. កាត់បន្ថយ

ចម្លើយ៖ 2

សំណួរទី 7
តើច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាតមានគោលបំណងអ្វី?

1. ផ្គត់ផ្គង់ទឹកដែលមានតម្លៃថោក
2. ផ្គត់ផ្គង់ទឹកដែលមានតម្លៃថ្លៃ
3. ផ្គត់ផ្គង់ទឹកដែលមិនស្អាត

ចម្លើយ៖ 1

សំណួរទី 8

តើច្បាប់អ្វីខ្លះដែលចែងអំពីការងារសំណង់និងការរក្សាសុវត្ថិភាពនៃបរិក្ខារអគ្គិសនី?

1. ច្បាប់ស្តីពីអាជីវកម្មហ្គាស
2. ច្បាប់ស្តីពីអាជីវកម្មទូរគមនាគមន៍
3. ច្បាប់ស្តីពីរលកវិទ្យុ
4. ច្បាប់ស្តីពីអាជីវកម្មអគ្គិសនី

ចម្លើយ៖ 4

សំណួរទី 9
តើការងារសំណង់អគារគឺមួយណា?

1. ការងារសាងសង់លំនៅដ្ឋាន
2. ការងារសាងសង់ផ្លូវ
3. ការងារសាងសង់ទំនប់អាងទឹក

ចម្លើយ៖ 1

# វិញ្ញាសាគំរូ ការប្រឡងវាយតម្លៃពលករជំនាញកម្រិត 1 ផ្នែកសំណង់ (ការប្រឡងទ្រឹស្តី)

សំណួរទី 10
តើឧបករណ៍ក្នុងរូបថតគឺជាមួយណាក្នុងចំណោមខាងក្រោមនេះ?

1. ឧបករណ៍ការពារជម្រាបទឹក
2. ឧបករណ៍បំបែករញ្ជួយ
3. ឧបករណ៍កំណត់បរិយាកាសខាងក្នុង



ចម្លើយ៖ 2

សំណួរទី 11
តើការងារសំណង់ដែលពាក់ព័ន្ធនឹងអគ្គិសនី ហ្គាស ទឹកស្អាត អ៊ីនធឺណិតជាដើម ហៅថាអ្វី?

1. ការងារសំណង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន
(lifeline)
2. ការងារសំណង់អគារ
3. ការងារសំណង់ស៊ីវិល

ចម្លើយ៖ 1

សំណួរទី 12
ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង(　　　　　) ក្នុងប្រយោគខាងក្រោម។
ការងារជីកដីបង្កើតអណ្ដូងហៅថា (　　　　　)។

1. ការងារជីក
2. ការសាងសង់ផ្លូវរូង
3. ការងារខួងអណ្ដូង
4. ការងារជីករណ្ដៅ

ចម្លើយ៖ 3

សំណួរទី 13
តើវិធីសាស្ត្រសសរគ្រឹះផលិតជាស្រេច គឺជាមួយណាក្នុងចំណោមខាងក្រោមនេះ?

1. វិធីសាស្ត្រដែលដឹកជញ្ជូនសសរគ្រឹះដែលផលិតនៅរោងចក្រមកការដ្ឋានដើម្បីវាយបញ្ចូល
2. វិធីសាស្ត្រដែលផលិតសសរគ្រឹះនៅការដ្ឋានសំណង់
3. វិធីសាស្ត្រដែលប្រើប្រាស់ឡើងវិញនូវសសរគ្រឹះដែលបានប្រើប្រាស់រួចហើយ
4. វិធីសាស្ត្រដែលផលិតសសរដោយចាក់បេតុងលាយស្រេចចូលក្នុងរន្ធ

ចម្លើយ៖ 1

សំណួរទី 14
ការងារដំឡើងគ្រោងសំណង់ដូចជាសសរនិងធ្នឹមជាដើមដោយប្រើឆ្អឹងដែក គឺហៅថាអ្វី?

1. ការងារសរសៃដែក
2. ការងារពុម្ព
3. ការងារតសរសៃដែក
4. ការងារឆ្អឹងដែក

ចម្លើយ៖ 4

សំណួរទី 15
តើការងារសំណង់ដែលបង្កើតពុម្ពសម្រាប់បញ្ចូលបេតុងជុំវិញសរសៃដែក គឺមួយណាក្នុងចំណោមខាងក្រោម?

1. ការងារសរសៃដែក
2. ការងារតសរសៃដែក
3. ការងារពុម្ព
4. ការងារស៊ីមបង្អួច

ចម្លើយ៖ 3

# វិញ្ញាសាគំរូ  ការប្រឡងវាយតម្លៃពលករជំនាញកម្រិត 1 ផ្នែកសំណង់ (ការប្រឡងទ្រឹស្តី)

សំណួរទី 16
ក្នុងរូបថតនេះ តើគេកំពុងធ្វើការងារអ្វី?

1. ការងារចាក់បេតុង
2. ការងារជីដោយម៉ាស៊ីន
3. ការងារស៊ុមទ្វារបង្អួចលោហៈ
4. ការងារដំបូល



ចម្លើយ៖ 1

សំណួរទី 17
ចូរជ្រើសរើសគុណវុឌ្ឍិចាំបាច់ដើម្បីអនុវត្តការងារអគ្គិសនី។

1. អ្នកជំនាញការងារអគ្គិសនី
2. អ្នកជំនាញដំឡើង
3. វិស្វករបង្គោលទូរគមនាគមន៍
4. អ្នកជំនាញបរិក្ខារការពារអគ្គីភ័យ

ចម្លើយ៖ 1

សំណួរទី 18
ចូរជ្រើសរើសបរិក្ខារដែលត្រូវបានដំឡើងក្នុងការងារបរិក្ខារការពារអគ្គីភ័យ។

1. ឡាប្អូលាងមុខ
2. ឡដុត
3. ឧបករណ៍បាចសាចទឹក
4. ម៉ាស៊ីនត្រជាក់

ចម្លើយ៖ 3

សំណួរទី 19
ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង( ) ក្នុងប្រយោគខាងក្រោម។
ការងារ( )អគារឬសំណង់ត្រូវបានគេហៅថា ការងាររុះរើ។

1. បង្កើត
2. ជួសជុល
3. ដំឡើង
4. រុះរើ

ចម្លើយ៖ 4

សំណួរទី 20
ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង(          ) ក្នុងប្រយោគខាងក្រោម។
ក្នុងការងារសំណង់ មានការងារដែលត្រូវការ(          )។

1. ប័ណ្ណអនុញ្ញាត(ពែកមី)
2. លិខិតឆ្លងដែន
3. បណ្ណស្នាក់នៅ

ចម្លើយៈ 1

សំណួរទី 21

ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង(　　　　) ក្នុងប្រយោគខាងក្រោម។

ការបណ្តុះបណ្តាលពិសេសមានវិធី 2យ៉ាង គឺនៅក្រៅក្រុមហ៊ុន និងអនុវត្ត(　　　　)។

1. នៅបរទេស
2. ដោយក្រុមហ៊ុន
3. មន្ទីរការងារ

ចម្លើយ៖ 2

សំណួរទី 22
ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង (            ) ក្នុងប្រយោគខាងក្រោម។

ដើម្បីបង្ហាញពីក្តីសង្ឃឹមថានឹងមិនមានគ្រោះថ្នាក់ឬរបួសហើយការងារប្រចាំថ្ងៃនឹងប្រព្រឹត្តទៅដោយរលូន គេប្រើប្រាស់ការកិច្ចដែលនិយាយថា(            )។

1. សូមថៃខ្លួន
2. សូមឲ្យមានសុវត្ថិភាព(Goanzenni)
3. សូមប្រុងប្រយ័ត្ន

ចម្លើយ៖ 2

សំណួរទី 23
ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង (　　　　) ក្នុងប្រយោគខាងក្រោម។

ពាក្យថា(　　　　) អាចប្រើបានមិនត្រឹមតែនៅការដ្ឋានសំណង់ប៉ុណ្ណោះទេ គឺទាំងពេលដែលអ្នកដើរកាត់ជួបគ្នានៅក្នុងទីស្នាក់ការ កន្លែងសម្រាកជាដើមផងដែរ។

1. លាហើយ
2. មិនអីទេ មិនបាច់អរគុណទេ
3. អ្នកបាននឿយហត់ហើយ(Otsukaresamadesu)

ចម្លើយ៖ 3

សំណួរទី 24
គំនូសដែលគូសដោយផ្ទាល់ទៅលើផ្ទៃរាបដូចជាកម្រាលបាតជាដើម តើហៅថាអ្វី?

1. គំនូសបញ្ឈរ
2. ខ្សែគូសគេច
3. គំនូសសម្រេច
4. គំនូសលើបាត

ចម្លើយ៖ 4

សំណួរទី 25
ការបង្កើតផ្ទៃដីរាបស្មើដោយចាក់លើកដីជម្រាល ដីមិនរាបស្មើ ឬដីទាប ដោយដីខ្សាច់ គឺហៅថាអ្វី?

1. ការជីករណ្តៅគ្រឹះ
2. ការលើកដី
3. ការលុបដីវិញ
4. ការជីកដោយមិនទប់ដី

ចម្លើយ៖ 2

សំណួរទី 26
កម្លាតពីសរសៃដែកទៅផ្ទៃលើបេតុងដែលស្រោបវា ហៅថាអ្វី?

1. កម្លាត(សរសៃដែក)
2. ចន្លោះទំនេរ
3. កម្រាស់បេតុងការពារសរសៃដែក
4. កម្លាត(ចំណុចកណ្ដាលសរសៃដែក)

ចម្លើយ៖ 3

សំណួរទី 27
តើពាក្យមួយណាដែលប្រើក្នុងការងារហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន(lifeline)/បរិក្ខារ ហើយមានន័យថាជាការលៃតម្រូវសីតុណ្ហភាព កម្រិតសំណើមជាដើមនៅក្នុងបន្ទប់?

1. ការកំណត់បរិយាកាសខាងក្នុង(គូឆូ)
2. ការផ្លាស់ប្តូរខ្យល់
3. ការបញ្ចេញចោលផ្សែង
4. អនាម័យ

ចម្លើយ៖ 1

សំណួរទី 28

ស5 ដែលដើម្បីបង្កើតបរិយាកាសការងារប្រកបដោយសុវត្ថិភាព ភាពរីករាយនិងងាយស្រួលធ្វើការងារ គឺមាន សម្រិតសម្រាំង(Seiri ) សណ្តាប់ធ្នាប់(Seiton ) សម្អាត(Seisou ) ស្តង់ដារ(Seiketsu ) និងមួយទៀតគឺជាអ្វី?

1. ជួសជុល (Syuri)
2. ពិគ្រោះយោបល់ (Soudan)
3. ស្ថិតស្ថេរ(Shitsuke)

ចម្លើយ៖ 3

សំណួរទី 29
តើមួយណាដែលត្រឹមត្រូវក្នុងនាមជាវិន័យនៅទីសំណាក់កម្មករ?

1. ការជក់បារីគឺត្រូវជក់ដោយលាក់ខ្លួននៅកន្លែងដែលគ្មានអ្នកណាឃើញ
2. បើប្រទះឃើញសំរាមជ្រុះ ត្រូវទុកទាំងបែបនោះ
3. ទុកដាក់មួកសុវត្ថិភាព និងខ្សែក្រវាត់សុវត្ថិភាពនៅកន្លែងដែលបានកំណត់

ចម្លើយ ៖ 3